# រឿងនន្ទយក្ខ

( គុណនៃសមាបត្តិ ពូកែផុតក្នុងលោក )

ក្នុងកាលខ្លះ ព្រះអគ្គសាវកទាំងពីរអង្គសម្រាកសម្រាន្តព្រះឥរិយាបថ ក្នុងបោតកន្ទវិហារក៏មាន ។ នាកាលរាត្រីខាងខ្នើតព្រះចន្ទបានបញ្ចាំងរស្មីភ្លឺត្រដះឆើតឆាយជាទីនាំចិត្តរបស់សត្វទាំងឡាយឲ្យរីករាយ សប្បាយទូទៅគ្រប់ភូមិស្រុកទាំងអស់ ។

ឯព្រះសាវៈកទាំងពីរអង្គនោះ ព្រះសារីបុត្តដ៏មានអាយុជាព្រះធម្ម សេនាបតី ទើបនឹងកោរព្រះកេស ( សក់ ) ថ្មី គង់ចូលសមាបត្តិជាសប្បាយក្នុងឪរាវាលស្រឡះ ។ លំដាប់នោះ នន្ទយក្ខព្រមនឹងយក្ខមួយទៀត ហោះហើរលើអាកាស៍ បានឃើញព្រះថេរគង់ចូលសមាបត្តិក្នុងទីវាលដូច្នោះ ក៏បណ្ដាលចិត្តសាហាវឃោរឃៅ អាក្រក់ក្រៃឲ្យកើតឡើង ។ តែតាមដំណឹងមកថា យក្ខនោះមានគំនុំគំគួននឹងព្រះថេរក្នុងជាតិដែលមានក្នុងកាលមុន ។

នន្ទយក្ខមានចិត្តទ្រឹស្នួរកើតឡើងហើយ ចង់វាយព្រះសិរព្រះថេរណាស់ ហើយនិយាយប្រាប់យក្សមួយទៀតថា សំឡាញ់អញចង់វាយក្បាលលោកនោះណាស់ ។ នៃ សំឡាញ់កុំលោកនុងមានអំណាចណាស់វាយមួយផ្ទូងនៅដដែល ។ នន្ទយក្ខមិនអើពើនឹងសំដីឃាត់សោះ ទើបបណ្ដាលឲ្យសេចក្ដីឧស្សាហ៍ឲ្យកើតឡើង ហើយឈរជ្រែងលើអាកាសសំពងព្រះសិរព្រះថេរលាន់ឮផ្ទូង ខ្លាំងអស្ចារ្យហួសការប្រហារធម្មតា ។ ការប្រហារនោះ អាចពន្លិតចុះនូវនាគមានពូជ ៧ ឬ ៧កន្លះ ពុំនោះសោត កំពូលភ្នំដ៏ធំក៏ស្រុតចុះចូលទៅក្នុងផែនដីបានដែរ ។ ប៉ុន្តែគ្រោះល្អបានកំឡាំងសមាបត្តិជួយគាំទ្រ ព្រះសិររបស់លោកពុំមានស្លាកស្នាមអ្វីឡើយ ជួនជាពេលដែលយក្ខប្រហារនោះទៀត លោកមិនទាន់ចេញពីសមាបត្តិ ។ ព្រះមហាមោគ្គល្លានមានឫទ្ធិច្រើន បានឃើញយក្ខនោះប្រហារព្រះសារីបុត្រដោយទិព្វចក្ខុហើយចូលទៅរកលោក ។

ព្រះមហាមោគ្គល្លានសួរថា ហៃអាវុសោសារីបុត្តលោកឈឺដែរឬទេ ? ទេ អាវុសោមោគ្គល្លានសរីរយន្តរបស់ខ្ញុំល្មមទ្រាំបាន ល្មមឲ្យប្រព្រឹត្តទៅបានតែឈឺបន្តិចដែរ ។ គួរតែឆ្ងល់ខានពុំបាន បើសរីរបានកំឡាំងសមាបត្តិជួយឧបត្ថម្ភហើយ ម្ដេចឡើយបានជាមានសេចក្ដីឈឺចាប់បន្តិចបន្តួចក្នុង ព្រះសិរព្រះថេរដែរ ? បានជាឈឺចាប់ព្រោះលោកប្រញាប់ចេញមកពីសមាបត្តិពេក ព្រោះថាសេចក្ដីទុក្ខរមែងមិនប្រាកដខាងក្នុងសមាបត្តិទេ ដូចជាបុគ្គលដេកលក់ហើយសត្វទាំងឡាយមានមុសជាដើមខាំ លុះភ្ញាក់ឡើងលែងអ្វីនឹងមានសេចក្ដីឈឺ ។

ឯនន្ទយក្សគ្រាន់តែវាយព្រះថេរហើយភ្លាម ក៏មានសេចក្ដីក្ដៅអន្ទះអន្ទែងដ៏ខ្លាំងក្លាកើតឡើងក្នុងសរីរ ទើបស្រែកថា អញនេះហើយ អញឆេះហើយ ហើយធ្លាក់ដាំដូងមកពីអាកាសផែនដី ស្រាប់តែអណ្ដែតភ្លើងអវិចីស្រោបពេញអត្តភាព ហើយអូសទំលាក់ទៅក្នុងនរកទាំង

ស្រស់ ។ គួរឆ្ងល់ម្តងទៀតហើយ ហេតុអ្វីបានជាភ្លើងអវិចីរុញគ្នាទៅនរកទាំងអត្តភាពជាយក្ខដូច្នេះ ម្តេចមិនចាំស្លាប់សិន ឆ្លើយថាបាបកម្ម ជាទិដ្ឋធម្មវេទនីយ ( សត្វសម្បីសោយក្នុងបច្ចុប្បន្ន ) ណាមានយក្ខ ត្រូវសោយនូវមហាទុក្ខទាំងអត្តភាពជាយក្សដោយកំឡាំងនៃបាបកម្ម ជាទិដ្ឋធម្មវេទនីយនោះ មិនចាំបាច់ដល់ស្លាប់ឡើយ អាចសោយទាំងរស់បានដោយឥតញញើត ។ ឯនន្ទយក្សនោះក៏ចូលទៅកើតក្នុងអនន្តរិយកម្ម ដែលត្រូវវងក្នុងភពជាលំដាប់តទៅ ។

សូមអស់លោកអ្នកអនុមោទនា !

ចប់